ASIAN-PACIFIC
CONGRESS on EVANGELISM
SYDNEY 2027

# សេចក្តីប្រកាសព័ត៌មាន

## សម្រាប់ផ្សព្វផ្សាយភ្លាមៗ

## នឹងរៀបចំឡើងនៅខែសីហា ឆ្នាំ២០២៧៖<br>មហាសន្និបាតសម្រាប់ការផ្សាយដំណឹងល្អនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក

***មហាសន្និបាតអាស៊ីប៉ាស៊ីហ្វិកស្តីពីការផ្សាយដំណឹងល្អ នឹងប្រព្រឹត្តទៅពីថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៧ នៅទីក្រុងស៊ីដនី។***

**សម្រាប់ទំនាក់ទំនងផ្នែកផ្សព្វផ្សាយ:** media@billygraham.org

**ក្រុងស៊ីដនី ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៥** — នៅពីរឆ្នាំខាងមុខ គេរំពឹងថាថ្នាក់ដឹកនាំគ្រីស្ទបរិស័ទចំនួន ២.៥00នាក់ ដែលមកពីបណ្តាប្រទេស និងដែនដីជាង ៥0 នៅទូទាំងតំបន់អាស៊ី និងប៉ាស៊ីហ្វិក ចាប់ពីប្រទេសអូស្ត្រាលីរហូតដល់អាហ្វហ្គានីស្ថាន និងពីប្រទេសកម្ពុជារហូតដល់ប្រទេសចិន នឹងប្រមូលផ្តុំគ្នានៅទីក្រុងស៊ីដនី សម្រាប់មហាសន្និបាតអាស៊ីប៉ាស៊ីហ្វិកស្តីពីការផ្សាយដំណឹងល្អ។

ក្នុងអំឡុងពេលបីថ្ងៃ និងមានការបកប្រែជាង ១0ភាសា ក្រុមគ្រូគង្វាល អ្នកផ្សាយដំណឹងល្អ និងថ្នាក់ដឹកនាំព័ន្ធកិច្ចគ្រប់វ័យ នឹងជួបជុំគ្នាដើម្បីទទួលបានការលើកទឹកចិត្ត ការដាស់តឿន និងការបំពាក់បំប៉ន ដើម្បីនាំយកដំណឹងល្អដោយក្លាហានទៅកាន់ទីកន្លែងដែលមនុស្សរាប់ពាន់លាននាក់នៅមិនទាន់បានស្គាល់ព្រះយេស៊ូវគ្រីស្ទ។

លោកគ្រូគង្វាល ហេង ចេង ប្រធានសម្ព័ន្ធក្រុមជំនុំផ្សាយដំណឹងល្អកម្ពុជា បានមានប្រសាសន៍ថា៖ *«មហាសន្និបាតអាស៊ីប៉ាស៊ីហ្វិកនេះ ប្រព្រឹត្តទៅក្នុងពេលវេលាដ៏សំខាន់មួយសម្រាប់ប្រទេសកម្ពុជា និងសម្រាប់តំបន់ទាំងមូល។ មហាសន្និបាតនេះមានគោលបំណងលើកទឹកចិត្ត និងបំពាក់បំប៉នគ្រីស្ទបរិស័ទ ដើម្បីនាំយកដំណឹងល្អទៅកាន់សហគមន៍របស់ពួកគេ តាមរយៈពាក្យសម្តី និងសកម្មភាពជាក់ស្តែង»។*

លោកបានបន្តថា៖
*«ការផ្សាយដំណឹងល្អចាប់ផ្តើមនៅពេលដែលអ្នកជនទៃមើលឃើញសេចក្តីអំណរនៃជីវិតថ្មីក្នុង
ព្រះគ្រីស្ទ បានឆ្លុះបញ្ចាំងនៅក្នុងគ្រួសារ និងទំនាក់ទំនងប្រចាំថ្ងៃ។
មហាសន្និបាតនេះរំឭកយើងថា ការចែករំលែកដំណឹងល្អ និងការបង្កើតសិស្ស
គឺជាកិច្ចការដែលត្រូវដើរទន្ទឹមគ្នា
ហើយក៏ដាស់តឿនគ្រីស្ទបរិស័ទគ្រប់រូបឲ្យរស់នៅតាមសាររបស់ព្រះយេស៊ូវ
ដោយចិត្តខ្នះខ្នែងជាថ្មី និងដោយសាមគ្គីភាព»។*

លោក ហ្វ្រេងគ្លីន ហ្គ្រេហាំ (**Franklin Graham**) ប្រធាន
និងជានាយកប្រតិបត្តិរបស់សមាគមផ្សាយដំណឹងល្អប៊ីលី្ល ហ្គ្រេហាំ (**BGEA)**
និងជាអ្នករៀបចំមហាសន្និបាតនេះ បានមានប្រសាសន៍ថា៖
«នេះគឺជាពេលវេលាដ៏សំខាន់ជាដាច់ខាតសម្រាប់ក្រុមជំនុំនៅទូទាំងតំបន់អាស៊ី
និងប៉ាស៊ីហ្វិក។
យើងចង់ដុតបញ្ឆេះភ្លើងដ៏បរិសុទ្ធនៅក្នុងដួងចិត្តរបស់គ្រីស្ទបរិស័ទជំនាន់ក្រោយមួយទៀត
ដែលនឹងបន្តកាន់ស្មារតីនៃដំណឹងល្អដែលជាក្តីសង្ឃឹម
ឆ្ពោះទៅកាន់គ្រប់កោះដាច់ស្រយាលក្នុងព្រៃជ្រៅ គ្រប់ទីក្រុងដ៏អ៊ូអរ
និងគ្រប់ភូមិដាច់ស្រយាលលើតំបន់ភ្នំ។

លោកបានបន្តថា៖ «វាគឺជាកិត្តិយសសម្រាប់យើងខ្ញុំ ដែលបានមកចូលរួម
និងលើកទឹកចិត្តដល់បងប្អូនជឿព្រះនៅតំបន់នេះនៃពិភពលោក
ឲ្យនាំយកដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទទៅដោយគ្មានសេចក្តីភ័យខ្លាច
រហូតដល់ចុងផែនដីបំផុត»។

**ការពង្រឹងមូលដ្ឋានគ្រឹះពីមហាសន្និបាតនៅក្រុងប៊ែរឡាំង និងមហាសន្និបាតមុនៗទៀត**
មហាសន្និបាតពិភពលោកលើកទីមួយស្តីពីការផ្សាយដំណឹងល្អរបស់សមាគម BGEA
ត្រូវបានប្រារព្ធឡើងនៅក្រុងប៊ែរឡាំង ប្រទេសអាល្លឺម៉ង់ ក្នុងឆ្នាំ១៩៦៦។ បន្ទាប់មក
មហាសន្និបាតផ្សាយដំណឹងល្អជាបន្តបន្ទាប់ទៀត ក៏ត្រូវបានធ្វើឡើងនៅក្រុងអាំស្ទែរដាំ
ក្នុងឆ្នាំ១៩៨៣, ១៩៨៦ និងឆ្នាំ២០០០។

មហាសន្និបាតអាស៊ីប៉ាស៊ីហ្វិកនេះ ធ្វើឡើងបន្តពីមហាសន្និបាតអឺរ៉ុបស្តីពីការផ្សាយដំណឹងល្អ
ដែលត្រូវបានប្រារព្ធឡើងកាលពីខែឧសភាកន្លងទៅនេះ នៅក្រុងប៊ែរឡាំង
ប្រទេសអាល្លឺម៉ង់។ ថ្នាក់ដឹកនាំគ្រីស្ទបរិស័ទជាង ១.០០០នាក់ មកពី ៥៥ប្រទេសនៅអឺរ៉ុប
បានជួបជុំគ្នាដើម្បីបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់ពួកគេ
ក្នុងការប្រកាសដំណឹងល្អដោយឥតខ្មាសអៀន។ ដោយចិត្តឆេះឆួល
អ្នកចូលរួមជាច្រើនបានលើកឡើងថា ពួកគេទន្ទឹងរង់ចាំវិលត្រឡប់ទៅផ្ទះវិញយ៉ាងអន្ទះសា
ដើម្បីចែករំលែកសេចក្តីសង្ឃឹមនៃឈើឆ្កាងនៅក្នុងសហគមន៍របស់ពួកគេ។

គ្រូគង្វាលម្នាក់បានត្រឡប់ទៅប្រទេសអ៊ីតាលីវិញ
ដោយប្តេជ្ញាចិត្តថានឹងផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើការអធិស្ឋាន
និងការអញ្ជើញឲ្យទទួលជឿដំណឹងល្អ។ លោកបានធ្វើដូច្នោះមែន
ក្នុងអំឡុងពេលបោះជំរុំសម្រាប់យុវជន ហើយយុវជនចំនួន ៤០នាក់
បានថ្វាយជីវិតរបស់ពួកគេដល់ព្រះយេស៊ូវគ្រីស្ទ។

លោកគ្រូគង្វាល ដានី ប៉ាស្កាល (Danny Pasquale) បានមានប្រសាសន៍ថា៖
«ការបានចូលរួមក្នុងមហាសន្និបាតនេះ
បានជួយឲ្យខ្ញុំយល់កាន់តែច្បាស់អំពីសារៈសំខាន់នៃការអញ្ជើញឲ្យទទួលជឿ

និងបានផ្ដល់ឲ្យអ្នកចូលរួមជំរំនូវវិធីជាក់លាក់មួយដើម្បីឆ្លើយតប»។ លោកបានបន្ថែមថា៖ «យើងក៏បានផ្ដោតបន្ថែមទៀតលើការអធិស្ឋាន ដោយអធិស្ឋានសូមឲ្យដំណឹងល្អអាចជះឥទ្ធិពលពិតប្រាកដដល់ជីវិតរបស់អ្នកចូលរួមការបោះជំរុំ»។

**ការដុតបញ្ឆេះភ្លើងនៃដំណឹងល្អនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក**

មនុស្សប្រមាណបួនពាន់លាននាក់រស់នៅក្នុងតំបន់នេះនៃពិភពលោក ដែលក្នុងនោះមានប្រជាជនតិចជាង ១០ភាគរយជាគ្រីស្ទបរិស័ទ។

លោកគ្រូគង្វាល កានីសកា រ៉ាហ្វែល **(Kanishka Raffel)** អគ្គអាចារ្យនៃព្រះសហគមន៍និកាយអង់គ្លីកង់ប្រចាំក្រុងស៊ីដនី ដែលថ្មីៗនេះបានថ្លែងនៅក្នុងមហាសន្និបាតអឺរ៉ុបស្ដីពីការផ្សាយដំណឹងល្អរបស់សមាគម BGEA បានមានប្រសាសន៍ថា៖ «មហាសន្និបាតនៅក្រុងប៉ែរឡាំងបានបន្សល់ទុកឲ្យយើងនូវចិត្តឆេះឆួលជាមួយនឹងចក្ខុវិស័យរួមគ្នា គឺដើម្បីបានឃើញដំណឹងល្អត្រូវបានប្រកាសដោយភាពក្លាហាន និងភាពច្បាស់លាស់។ ឥឡូវនេះ អ្នកផ្សាយដំណឹងល្អមកពីទ្វីបអាស៊ី អូសេអានី និងអូស្ត្រាឡាស៊ី នឹងប្រមូលផ្ដុំគ្នានៅប្រទេសអូស្ត្រាលី ដើម្បីបំពេញភារកិច្ចតែមួយ និងការត្រាស់ហៅតែមួយរបស់យើង គឺការធ្វើឲ្យគេបានស្គាល់ព្រះគ្រីស្ទ។ យើងមានឱកាសដ៏រុងរឿងនៅអូស្ត្រាលី និងអាស៊ីប៉ាស៊ីហ្វិក ចូរយើងកុំខ្ជះខ្ជាយពេលវេលានេះឡើយ»។

ការចូលរួមក្នុងមហាសន្និបាតអាស៊ីប៉ាស៊ីហ្វិកស្ដីពីការផ្សាយដំណឹងល្អ គឺតាមរយៈការអញ្ជើញតែប៉ុណ្ណោះ។ គ្រីស្ទបរិស័ទត្រូវបានលើកទឹកចិត្តឲ្យចាប់ផ្ដើមអធិស្ឋានសម្រាប់មហាសន្និបាតនេះ ហើយព័ត៌មានបន្ថែមនឹងមានផ្ដល់ជូនក្នុងរយៈពេលប៉ុន្មានខែខាងមុខនេះ។

**ប្រសាសន៍បន្ថែមពីថ្នាក់ដឹកនាំក្រុមជំនុំ**

- **សិង្ហបុរី | លោកគ្រូគង្វាល អេដម៉ាន់ ចាន់ (Edmund Chan) ស្ថាបនិក និងជាអ្នកណែនាំផ្នែកភាពជាអ្នកដឹកនាំនៃសម្ព័ន្ធសកលនៃក្រុមជំនុំបង្កើតសិស្សដោយចេតនា (Global Alliance of Intentional Disciple-making Churches)**

  «ការបង្កើតសិស្សដោយគ្មានការផ្សាយដំណឹងល្អ ប្រៀបដូចជាមនុស្សពិការភ្នែក។ រីឯការផ្សាយដំណឹងល្អដោយគ្មានការបង្កើតសិស្ស គឺប្រៀបដូចជាមនុស្សខ្វិនខ្វង់។ ដូច្នេះហើយ ខ្ញុំពិតជារំភើបយ៉ាងខ្លាំងចំពោះមហាសន្និបាតអាស៊ីប៉ាស៊ីហ្វិកស្ដីពីការផ្សាយដំណឹងល្អ ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី ក្នុងឆ្នាំ២០២៧ខាងមុខនេះ។ ពិតជាមានតម្រូវការដ៏ធំធេងសម្រាប់ដំណឹងល្អនៅក្នុងតំបន់នេះនៃពិភពលោក។ ក្នុងនាមជាសហគមន៍ដែលត្រូវបានប្រោសលោះ យើងម្នាក់ៗអាចធ្វើចំណែករៀងៗខ្លួនបាន គឺអ្នកខ្លះសាបព្រោះ អ្នកខ្លះស្រោចទឹក ហើយអ្នកខ្លះច្រូតកាត់ ហើយគ្រប់ការទាំងអស់គឺដើម្បីសិរីរុងរឿងរបស់ព្រះជាម្ចាស់ (១ កូរិនថូស ៣:៥-៩)!»។

- **ហ្វីលីពីន | លោកអភិបាល អេហ្វ្រាអិម អិម ថិនដេរ៉ូ (Efraim M. Tendero)**
  **ឯកអគ្គរដ្ឋទូតសកលនៃសម្ព័ន្ធផ្សាយដំណឹងល្អពិភពលោក**
  **និងជានាយកប្រតិបត្តិនៃចលនាកាលីឡេ**

  «យើងទទួលស្គាល់ពីតម្រូវការដ៏បន្ទាន់ក្នុងការប្រមូលផ្តុំ បំពាក់បំប៉ន
  និងពង្រឹងសមត្ថភាពដល់អ្នកជឿ ដើម្បីចែករំលែកដំណឹងល្អនៅក្នុងតំបន់មួយ
  ដែលជាលំនៅរបស់ប្រជាជនភាគច្រើនបំផុតនៅលើពិភពលោក
  និងមានចំនួនមនុស្សច្រើនជាងគេដែលមិនទាន់បានស្គាល់ព្រះគ្រីស្ទ។
  ចូរយើងរួមគ្នាងើបឡើងទទួលយកការប្រឈមនេះ ដោយប្រមូលផ្តុំ
  និងផ្តល់កម្លាំងដល់អ្នកធ្វើការផ្សាយដំណឹងល្អ ជំនាន់ថ្មី
  ដែលមានលក្ខណៈដូចព្រះគ្រីស្ទ គឺជាអ្នកប្រកាសដំណឹងល្អ និងជាអ្នកបង្កើតសិស្ស
  ដើម្បីផ្លាស់ប្តូរតំបន់អាស៊ីប៉ាស៊ីហ្វិកសម្រាប់ព្រះគ្រីស្ទ»។

- **ម៉ាឡេស៊ី | បណ្ឌិត ដានីយ៉ែល ហូ (Dr. Daniel Ho)**
  **គ្រូគង្វាលជាន់ខ្ពស់ស្ថាបនិកនៃក្រុមជំនុំមេតូឌីស ដាម៉ាន់សារ៉ា អ៊ូតាម៉ា**

  «បេសកកម្មរបស់ព្រះគ្រីស្ទក្នុងការស្វែងរក និងសង្គ្រោះអ្នកដែលបាត់បង់
  ត្រូវតែជាកិច្ចការចម្បងបំផុតរបស់យើង។
  បេសកកម្មនេះកាន់តែបន្ទាន់ជាខ្លាំងនៅក្នុងគ្រាដ៏មិនប្រាកដប្រជា

  និងពោរពេញដោយការប្រឈមនេះ
  នៅពេលដែលកំណើននៃក្រុមជំនុំទូទាំងសកលលោកបាននៅទ្រឹង
  ហើយមនុស្សរាប់មិនអស់ត្រូវបាត់បង់ទៅកាន់ជីវិតអស់កល្បជានិច្ចដែលគ្មានព្រះគ្រីស្ទ។ ឥឡូវនេះគឺជាពេលវេលាដែលក្រុមជំនុំត្រូវក្រោកឡើង
  ហើយប្រកាសអំពីសេចក្តីសង្ឃឹមដែលមានតែនៅក្នុងព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ!»។

- **ឥណ្ឌា | បណ្ឌិត រ៉ូប៊ីត ខាន់វីល (Dr. Robert Cunville)**
  **អ្នកផ្សាយដំណឹងល្អប្រចាំសមាគមផ្សាយដំណឹងល្អប៊ីលី្ល ហ្គ្រាហាំ**

  «ប្រទេសឥណ្ឌាបានឮដំណឹងល្អជាលើកដំបូងនៅក្នុងគ្រិស្តសករាជ ៥២
  តាមរយៈលោកថូម៉ាស់ ដែលជាសាវ័កម្នាក់របស់ព្រះយេស៊ូវគ្រីស្ទ
  ហើយនៅក្នុងគ្រិស្តសករាជ ៦៣
  ប្រទេសចិនបានឮដំណឹងល្អអំពីព្រះគ្រីស្ទជាលើកដំបូង។ ជិត
  ២.០០០ឆ្នាំបានកន្លងផុតទៅហើយចាប់តាំងពីពេលនោះមក
  ប៉ុន្តែមកដល់សព្វថ្ងៃនេះ
  នៅតែមានមនុស្សរាប់លាននាក់នៅក្នុងទ្វីបអាស៊ីដែលមិនទាន់បានឮដំណឹងល្អនៅឡើយ។
  នេះគឺជាមូលហេតុដែលខ្ញុំទន្ទឹងរង់ចាំដោយក្តីរំពឹងយ៉ាងខ្លាំងចំពោះមហាសន្និបាតនេះនៅទីក្រុងស៊ីដនី។
  ខ្ញុំអធិស្ឋានសូមឲ្យមហាសន្និបាតនេះនឹងដុតបញ្ឆេះឡើងវិញនូវចិត្តខ្នះខ្នែងរបស់យើង
  ដើម្បីបន្តប្រកាសអំពីសារដ៏សាមញ្ញនៃឈើឆ្កាង និងព្រះលោហិតរបស់ព្រះយេស៊ូវ
  នៅទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិក»។

- **ឥណ្ឌូណេស៊ី | លោកគ្រូគង្វាល ឆាលស៍ ចូណាន (Charles Jonan)**
  **ប្រធានផ្នែកព័ន្ធកិច្ចក្នុងសង្គមនៃក្រុមជំនុំ ហ្គេរេយ៉ា បេតអែល**

  «ព្រះយេស៊ូវមានបន្ទូលនៅក្នុងព្រះគម្ពីរយ៉ូហាន ៤:៣៥ ថា៖ "អ្នករាល់គ្នានិយាយថា នៅបួនខែទៀតទើបដល់រដូវច្រូតកាត់មែនទេ? ប៉ុន្តែខ្ញុំប្រាប់អ្នករាល់គ្នាថា ចូរងើយភ្នែកមើលវាលស្រូវចុះ គឺស្រូវទុំល្មមច្រូតកាត់បានហើយ!" ចូរយើងប្រមូលផ្តុំគ្នា ហើយបង្រួបបង្រួមដួងចិត្ត និងកិច្ចការរបស់យើង ដើម្បីប្រមូលផលខាងវិញ្ញាណដ៏ធំធេងនៅតំបន់អាស៊ីប៉ាស៊ីហ្វិក។ ផលច្រូតពិតជាមានច្រើនណាស់ ប៉ុន្តែអ្នកធ្វើការមានតិចណាស់»។

- **នូវែលសេឡង់ | បណ្ឌិត រ៉ូប៊ីត សៀគីម៉ូទូ (Dr. Robert Siakimotu)**
  **អ្នកផ្សាយដំណឹងល្អប្រចាំអង្គការ Open Air Campaigners និងជាសហស្ថាបនិកនៃព័ន្ធកិច្ច Polynesian Ministries**

  «វាហួសពេលយូរមកហើយ ដែលយើងត្រូវទទួលស្គាល់ពីព័ន្ធកិច្ចរបស់អ្នកផ្សាយដំណឹងល្អ និងការផ្សាយដំណឹងល្អនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ក្នុងនាមខ្ញុំជាអ្នកផ្សាយដំណឹងល្អ ម្នាក់ ដែលមានមូលដ្ឋាននៅប្រទេសនូវែលសេឡង់ និងកំពុងធ្វើការនៅទូទាំងតំបន់ប៉ាស៊ី ហ្វិកខាងត្បូង ខ្ញុំជឿជាក់ថាមហាសន្និបាតស្តីពីការផ្សាយដំណឹងល្អនេះ នឹងជួយលើកទឹក ចិត្ត និងជំរុញទឹកចិត្តដល់អ្នកផ្សាយដំណឹងល្អ និងក្រុមជំនុំ ឲ្យប្រកាសដំណឹងល្អដោយគ្មានសេចក្តីភ័យខ្លាច និងរៀបចំបំពាក់បំប៉នគ្រីស្ទបរិស័ទកាន់តែច្រើន ឲ្យចែករំលែកដំណឹង ល្អប្រកបដោយប្រសិទ្ធ ភាព នៅក្នុងតំបន់របស់យើងនេះ»។

- **កូរ៉េខាងត្បូង | បណ្ឌិត ប៊ីល្លី គីម (Billy Kim)**
  **ប្រធានក្រុមហ៊ុនផ្សព្វផ្សាយចុងបូព៌ាប្រចាំប្រទេសកូរ៉េ និងជាអ្នកបកប្រែសម្រាប់មហាសន្និបាតផ្សាយដំណឹងល្អរបស់លោកប៊ីល្លី ហ្គ្រេហាំ ក្នុងឆ្នាំ១៩៧៣ នៅទីក្រុងសេអ៊ូល**

  «សព្វថ្ងៃនេះ តម្រូវការសម្រាប់ការផ្សាយដំណឹងល្អនៅប្រទេសកូរ៉េ និងនៅទូទាំងតំបន់អាស៊ី ប៉ាស៊ីហ្វិក គឺកាន់តែបន្ទាន់ជាងពេលណាៗទាំងអស់។ នៅពេលដែលលទ្ធិលោកិយនិយមកំ ពុងរីកចម្រើន ហើយសេចក្តីស្រេកឃ្លានខាងវិញ្ញាណកាន់តែខ្លាំងឡើង យើងត្រូវបានត្រាស់ហៅឲ្យប្រកាសដំណឹងល្អដោយភាពក្លាហាន សេចក្តីមេត្តាករុណា និងចិត្តសុភាពរាបសា។ ខ្ញុំចង់លើកទឹកចិត្តជាពិសេសដល់គ្រូគង្វាលវ័យក្មេង ឲ្យសម្លឹងទៅមុខដោយក្តីរំភើប និងជំ នឿ។ សូមឲ្យមហាសន្និបាតនេះក្លាយជាកត្តាលីករដ៏មានឥទ្ធិពលមួយ សម្រាប់ការរស់ឡើងវិញខាង វិញ្ញាណ សាមគ្គីភាព និងការបង្កើតឲ្យមានចិត្តខ្នះខ្នែងជាថ្មី ដើម្បីបំពេញមហា បេសកកម្ម!

- **ហុងកុង | លោកគ្រូគង្វាល អេរិក តុង (Eric Tong)**
  **ប្រធានសន្និសីទបាទីស្ទនៃទីក្រុងហុងកុង**

  «ព្រះជាម្ចាស់កំពុងធ្វើចលនាកិច្ចការដ៏មានអំណាចមួយនៅទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិក ហើយមហាសន្និបាតស្តីពីការផ្សាយដំណឹងល្អដែលនឹងមកដល់នេះ គឺជាការឆ្លើយតបពីព្រះសម្រាប់ពេលវេលានេះ។

ការជួបជុំនេះគឺលើសពីព្រឹត្តិការណ៍មួយទៅទៀត—
វាគឺជាចលនាយុទ្ធសាស្ត្រមួយដើម្បីបង្រួបបង្រួមអ្នកជឿ បង្កើនជំនឿរបស់យើងឡើងវិញ
និងបំពាក់បំប៉នថ្នាក់ដឹកនាំជំនាន់ថ្មី
ដើម្បីប្រកាសព្រះនាមព្រះយេស៊ូវគ្រីស្ទដោយភាពក្លាហាន។
រលកថ្មីនៃការរស់ឡើងវិញខាងវិញ្ញាណកំពុងតែមកដល់
ហើយមហាសន្និបាតនេះនឹងក្លាយជាកត្តាលិកររបស់វា។ "មើល៍ អញធ្វើការថ្មីមួយ ឥឡូវនេះ
ការនោះនឹងពន្លកឡើង តើឯងរាល់គ្នាមិនដឹងទេឬ?" (អេសាយ ៤៣:១៩)»។

- **ម៉ុងហ្គោលី | លោកគ្រូគង្វាល អ៊ុកតាបាយ៉ា តូហ្គូប័រ (Ugtakhbayar Togoobor)**
  **គ្រូគង្វាលនៃក្រុមជំនុំគ្រីស្ទាន ទីក្រុងភ្លីស្វាង**

  «នៅពេលដែលប្រទេសម៉ុងហ្គោលីបានបើកចំហនៅដើមទសវត្សរ៍ឆ្នាំ១៩៩០
  គឺមានគ្រីស្ទបរិស័ទតែបួននាក់ប៉ុណ្ណោះនៅក្នុងប្រទេស។ តាមរយៈការប្រកាសដំណឹងល្អ
  សេចក្តីអំណរពិត តម្លៃនៃជីវិត
  និងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ត្រូវបានផ្សព្វផ្សាយទូទាំងប្រទេសម៉ុងហ្គោលី។
  ភ្លើងនៃដំណឹងល្អកំពុងត្រូវបានដុតបញ្ឆេះនៅក្នុងដួងចិត្តរបស់មនុស្សជំនាន់ក្រោយ
  ហើយខ្ញុំជឿជាក់ថាមហាសន្និបាតនេះនឹងក្លាយជាឥន្ធនៈ
  ដើម្បីដុតបញ្ឆេះឲ្យឆេះឡើងនូវចិត្តខ្នះខ្នែងដ៏យូរអង្វែងសម្រាប់ការផ្សាយដំណឹងល្អ
  មិនត្រឹមតែនៅក្នុងប្រទេសម៉ុងហ្គោលីប៉ុណ្ណោះទេ
  ប៉ុន្តែក៏នៅទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិកផងដែរ។
  ឥឡូវនេះគឺជាពេលវេលាដែលត្រូវមកជួបជុំគ្នា
  ហើយអធិស្ឋានសូមឲ្យព្រះអម្ចាស់បញ្ជូនអ្នកធ្វើការទៅក្នុងចំការដែលត្រូវច្រូតកាត់នៅតំបន់
  អាស៊ី និងប៉ាស៊ីហ្វិក»។

- **ប្រទេសថៃ | បណ្ឌិត វីរ៉ាដេត ជិតស័ក្កដាននូ (Veraded Jitsakdanont)**
  **ប្រធានគណៈកម្មាធិការផ្សាយដំណឹងល្អនៃប្រទេសថៃ**
  **និងជាប្រធានគណៈកម្មាធិការសម្របសម្រួលក្រុមជំនុំប្រូតេស្តង់នៃប្រទេសថៃ**

  «ខណៈពេលដែលក្រុមជំនុំថៃកំពុងដំណើរការអនុវត្តផែនការជាតិរួមគ្នាមួយ
  ដើម្បីនាំយកសេចក្តីពិតនៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ទៅកាន់ព្រះរាជាណាចក្រ
  របស់យើង
  វាធ្វើឲ្យខ្ញុំមានអំណរយ៉ាងខ្លាំងដែលបានដឹងថាសមាគមផ្សាយដំណឹងល្អប៊ីលី្ល ហ្គ្រេហាំ
  នឹងរៀបចំមហាសន្និបាតអាស៊ីប៉ាស៊ីហ្វិកស្តីពីការផ្សាយដំណឹងល្អ
  ដើម្បីបញ្ជាក់ពីភាពបន្ទាន់នៃការប្រកាសដំណឹងល្អ
  មិនត្រឹមតែនៅក្នុងប្រទេសថៃប៉ុណ្ណោះទេ ប៉ុន្តែក៏នៅទូទាំងតំបន់អាស៊ី
  និងប៉ាស៊ីហ្វិកផងដែរ។ នេះនឹងក្លាយជាការជួបជុំដ៏សំខាន់មួយសម្រាប់ទ្វីបអាស៊ី
  ដើម្បីបង្ហាញពីសាមគ្គីភាពរបស់ក្រុមជំនុំ និងភាពតែមួយនៃបេសកកម្មរបស់យើង
  គឺ "ចូរទៅផ្សាយដំណឹងល្អ" (ម៉ាកុស ១៦:១៥)»។

- **វៀតណាម | លោកគ្រូគង្វាល ហូ តាន់ខ្វា (Ho Tan Khoa)**
  **ប្រធានសម្ព័ន្ធក្រុមជំនុំផ្សាយដំណឹងល្អវៀតណាម**

  «ក្រុមជំនុំនៅប្រទេសវៀតណាមត្រូវបានបំពាក់បំប៉នដើម្បីប្រកាសដំណឹងល្អ
  តាមរយៈកិច្ច ការផ្សាយដំណឹងល្អជាច្រើន
  ដែលត្រូវបានរៀបចំឡើងដោយសេរីនៅតាមបណ្តាទីក្រុងជា ច្រើនទូ ទាំងប្រទេស
  ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ មហាសន្និបាតដែលនឹងមក ដល់នេះ

នឹងក្លាយជាសេចក្តីអំណរដ៏អស្ចារ្យ។ មហាសន្និបាតនេះនឹងបន្តបំពាក់បំប៉នក្រុម ជំនុំ និងរំឭកដល់អស់អ្នកជឿទាំងអស់នៅទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិក ឲ្យមានចិត្តក្លាហាន មិនខ្មាសអៀននឹងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទឡើយ»។

- **ជប៉ុន | លោកគ្រូគង្វាល យ៉ូស៊ីកាហ្ស៊ូ តាកាដា (Yoshikazu Takada) គ្រូគង្វាលចាស់ទុំនៃក្រុមជំនុំ ព្រះវិហារ ព្រះគ្រីស្ទ នូវែលសេឡង់ នីបប៉ុន អូសាកា និងជាប្រធានមជ្ឈមណ្ឌលបេសកកម្មជប៉ុន**

  «ដល់ពេលដែលស្បៃត្រូវតែបានបើកចេញហើយ។ មានប្រជាជន ១២៥លាននាក់រស់នៅក្នុងប្រទេសជប៉ុន ហើយមានវត្ថុជាច្រើនសម្រាប់គោរពបូជា។ ព្រះពិត និងផ្លូវទៅកាន់ជីវិតអស់កល្បជានិច្ច ត្រូវបានបិទបាំងពីប្រជាជនជប៉ុនអស់រយៈពេលរាប់រយឆ្នាំមកហើយ។ ប៉ុន្តែនៅក្នុងសៀវភៅយ៉ូហាន ១៤:៦ ព្រះយេស៊ូវមានបន្ទូលថា៖ "ខ្ញុំជាផ្លូវ ជាសេចក្តីពិត និងជាជីវិត។ គ្មានអ្នកណាអាចមកឯព្រះវរបិតាបានឡើយ លើកលែងតែមកតាមរយៈខ្ញុំ"។ នៅពេលដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់ត្រូវបានប្រកាសដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ នោះស្បៃនឹងត្រូវបានដកចេញ ហើយសិរីរុងរឿងរបស់ទ្រង់នឹងត្រូវបានបើកសម្តែង។ ខ្ញុំអធិស្ឋានសូមឲ្យសេចក្តីពិតនេះ នឹងបង្ហូរចុះមកដូចជាភ្លៀងនៃព្រះពររបស់ព្រះជាម្ចាស់ មកលើប្រទេសជប៉ុន និងតំបន់អាស៊ីប៉ាស៊ីហ្វិក។ យើងខ្ញុំរៀបចំ និងរង់ចាំការនេះដោយក្តីរំពឹងយ៉ាងខ្លាំង»។

**-ចប់-**

## កំណត់ចំណាំសម្រាប់អ្នកកែសម្រួល

## ឱកាសសម្រាប់ប្រព័ន្ធផ្សព្វផ្សាយ

- កញ្ចប់ឯកសារសម្រាប់អ្នកសារព័ត៌មាន (រួមមានរូបថត និងវីដេអូ)៖ Media.BillyGraham.org/Asian-Pacific-Congress-on-Evangelism
- សូមអញ្ជើញអ្នកសារព័ត៌មានចុះឈ្មោះចូលរួមមហាសន្និបាត ដែលនឹងប្រព្រឹត្តទៅនៅមជ្ឈមណ្ឌលសន្និបាតអន្តរជាតិស៊ីដនី (ICC Sydney) ដែលមានអាសយដ្ឋាន៖ 14 Darling Drive, Sydney NSW 2000។
- ការចុះឈ្មោះ និងការចូលរួមក្នុងកម្មវិធីសម្រាប់អ្នកសារព័ត៌មាន គឺមិនមានការគិតថ្លៃទេ ហើយអាហារក្នុងអំឡុងពេលមហាសន្និបាតក៏នឹងត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃផងដែរ។
- ដើម្បីបញ្ជាក់ពីការចូលរួម ឬសម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់៖ media@billygraham.org

## ប្រវត្តិនៃការផ្សាយដំណឹងល្អរបស់សមាគម BGEA នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក

សមាគមផ្សាយដំណឹងល្អប៊ីលី្ល ហ្គ្រេហាំ (BGEA) ដែលត្រូវបានបង្កើតឡើងដោយលោកប៊ីលី្ល ហ្គ្រេហាំ ក្នុងឆ្នាំ១៩៥០ មានបេសកកម្មចែករំលែកដំណឹងល្អអំពីព្រះយេស៊ូវគ្រីស្ទនៅជុំវិញពិភពលោក។ លោកប៊ីលី្ល ហ្គ្រេហាំ មានសេចក្តីស្រឡាញ់ និងការឲ្យតម្លៃយ៉ាងជ្រាលជ្រៅចំពោះតំបន់អាស៊ីប៉ាស៊ីហ្វិក ជាកន្លែងដែលលោកបានចែករំលែកដំណឹងល្អដល់មនុស្សជាង ១៣លាននាក់ ក្នុងមហាសន្និបាតផ្សាយដំណឹងល្អចំនួន ៣៥លើក។

កិច្ចការផ្សាយដំណឹងល្អជាប្រវត្តិសាស្ត្ររបស់លោកនៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េ ក្នុងឆ្នាំ១៩៧៣ មានអ្នកចូលរួមជាង ៣លាននាក់ ហើយគឺជាកម្មវិធីដ៏ធំបំផុតរបស់លោក។ នៅពេលលោកបានមកដល់ទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី ក្នុងឆ្នាំ១៩៥៩ មានមនុស្សជិត ៦០.០០០នាក់ បានសម្រេចចិត្តថ្វាយជីវិតដល់ព្រះគ្រីស្ទ។
លោក ហ្វ្រេងគ្លីន ហ្គ្រេហាំ ដែលជាកូនប្រុសរបស់លោក បានអធិប្បាយនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកចំនួន ៤១ដង ក្នុងរយៈពេល ៣៣ឆ្នាំកន្លងមកនេះ។ ថ្មីៗនេះ លោកគ្រូគង្វាល ហ្គ្រេហាំ ត្រូវបានអញ្ជើញឲ្យអធិប្បាយនៅប្រទេសវៀតណាម និងឡាវ ជាកន្លែងដែលមានមនុស្សរាប់ពាន់នាក់បានឆ្លើយតបនឹងដំណឹងល្អ។ លោក ហ្គ្រេហាំ ក៏កំពុងទន្ទឹងរង់ចាំអធិប្បាយនៅខេត្តសៀមរាប ប្រទេសកម្ពុជា ក្នុងឆ្នាំ២០២៦ និងនៅទីក្រុងហាណូយ ប្រទេសវៀតណាម ក្នុងឆ្នាំ២០២៧ខាងមុខនេះដែរ។

លោក វិល ហ្គ្រេហាំ ដែលជាកូនប្រុសរបស់លោក ហ្វ្រេងគ្លីន ហ្គ្រេហាំ ក៏មានចិត្តស្រឡាញ់យ៉ាងខ្លាំងចំពោះតំបន់នេះនៃពិភពលោកផងដែរ។ លោកបានរៀបចំកម្មវិធីផ្សាយដំណឹងល្អជាង ៣០លើក រួចមកហើយនៅតាមបណ្ដាប្រទេស និងដែនដីក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ហើយនឹងអធិប្បាយនៅប្រទេសជប៉ុន និងកូរ៉េ ក្នុងឆ្នាំ២០២៦។

**អំពីសមាគមផ្សាយដំណឹងល្អប៊ីលី្ល ហ្គ្រេហាំ**

សមាគមផ្សាយដំណឹងល្អប៊ីល្លី ហ្គ្រេហាំ ដែលត្រូវបានបង្កើតឡើងដោយលោកប៊ីល្លី ហ្គ្រេហាំ ក្នុងឆ្នាំ១៩៥០ មានបេសកកម្មចែករំលែកដំណឹងល្អអំពីព្រះយេស៊ូវគ្រីស្ទនៅជុំវិញពិភពលោក។

ចេញពីទីស្នាក់ការកណ្ដាលរបស់ខ្លួននៅទីក្រុងឆាឡុត រដ្ឋណតខារ៉ូឡាញ៉ា សមាគម BGEA ដឹកនាំព័ន្ធកិច្ចជាច្រើនទាំងក្នុងស្រុក និងអន្តរជាតិ ដែលរួមមានៈ កម្មវិធីផ្សាយដំណឹងល្អទ្រង់ទ្រាយធំ ដែលដឹកនាំដោយអ្នកផ្សាយដំណឹងល្អ ហ្វ្រេងគ្លីន ហ្គ្រេហាំ និង វិល ហ្គ្រេហាំ, បណ្ណាល័យប៊ីល្លី ហ្គ្រេហាំ, ខ្សែទូរស័ព្ទអធិស្ឋានប៊ីល្លី ហ្គ្រេហាំ (ដំណើរការ២៤ម៉ោង/៧ថ្ងៃ), មជ្ឈមណ្ឌលបណ្ដុះបណ្ដាលប៊ីល្លី ហ្គ្រេហាំ នៅ The Cove ដែលមានទីតាំងនៅក្រៅក្រុងអាសវីល រដ្ឋណតខារ៉ូឡាញ៉ា, ព្រមទាំងបម្រើព័ន្ធកិច្ចដល់អ្នកដទៃជាច្រើនទៀតតាមរយៈការបោះពុម្ព ទូរទស្សន៍ ទូរស័ព្ទ វិទ្យុ និងអ៊ីនធឺណិត។

គ្រូជំនួយស្មារតីដែលទទួលការបណ្ដុះបណ្ដាលផ្នែកវិបត្តិរបស់ក្រុមការងារប្រតិកម្មរហ័សប៊ីល្លី ហ្គ្រេហាំ ត្រូវបានបញ្ជូនទៅបេសកកម្មជាង ៤០លើកទៅកាន់បណ្ដាប្រទេសនៅតំបន់អាស៊ីប៉ាស៊ីហ្វិក ដើម្បីផ្ដល់ការគាំទ្រផ្នែកផ្លូវចិត្ត និងស្មារតីដល់ប្រជាជនដែលរងគ្រោះដោយគ្រោះមហន្តរាយ ដូចជាគ្រោះរញ្ជួយដីឆ្នាំ២០១១ នៅទីក្រុងសេនដៃ ប្រទេសជប៉ុន, ព្យុះទីហ្វុងឆ្នាំ២០១៤ នៅទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន និងគ្រោះថ្នាក់រត់ជាន់គ្នាដ៏រន្ធត់ក្នុងពិធីបុណ្យ Halloween ឆ្នាំ២០២២ នៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េ។

គម្រោងផ្សាយដំណឹងល្អតាមអ៊ីនធឺណិតរបស់សមាគម BGEA ឈ្មោះ SearchforJesus.net បានទៅដល់មនុស្សជាង ១០០លាននាក់នៅជុំវិញពិភពលោក ហើយបន្តផ្សារភ្ជាប់ទំនាក់ទំនងជាមួយមនុស្សរាប់សែននាក់នៅតំបន់អាស៊ីប៉ាស៊ីហ្វិកជារៀងរាល់ឆ្នាំ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ billygraham.org។